កាលបរិច្ឆេទ: ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៨

# មេរៀនដំណាំស្ពៃក្រញ៉ាញ់

## I. ប្រវត្តិសង្ខេបនៃការដាំស្ពៃក្រញ៉ាញ់

ដំណាំស្ពៃក្រញ៉ាញ់គឺជាដំណាំងាយស្រួលដាំជាងគេ ក្នុងចំណោមដំណាំផ្សេងៗទៀត។ វាគឺជាដំណាំឆ្លងកាត់ដែលកសិករយើងតែងបរិភោគជាប្រចាំ។

អាយុកាលដំណាំស្ពៃក្រញ៉ាញ់គឺចាប់រាប់តាំងពីពេលដាំឬពេលសាបព្រោះរហូតដល់ពេលប្រមូលផលប្រហែលជា២៧ទៅ៣០ថ្ងៃប៉ុណ្ណោះ។ យើងអាចប្រមូលផលវាបាននៅក្នុងកំឡុងពេលនេះ។ បន្ថែមពីនោះដំណាំនេះអាចយកទៅធ្វើជាបន្លែសម្រាប់បរិភោគឬសម្រាប់លក់ដូរនៅឯទីផ្សារក៏បាន។

## II. តម្រូវការអាកាសធាតុ

ដំណាំស្ពៃក្រញ៉ាញ់ត្រូវការកំដៅចាប់ពី៨០ទៅ១០០ភាគរយ ដើម្បីទ្រទ្រង់សរីរាង្គរបស់វា។ លើសពីនោះទៅទៀត ដំណាំនេះក៏ត្រូវការទឹកនិងសំណើមត្រជាក់ជាអចិន្ត្រៃយ៍ផងដែរ ដើម្បីធ្វើឱ្យវាលូតលាស់បានល្អនិងឆាប់បានទទួលផល។

---

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

## III. ទីតាំងដាំដុះ

មុនពេលដាំស្ពៃក្រញ៉ាញ់ យើងត្រូវជ្រើសរើសទីតាំងដីណាដែលអាចគេចផុតពីដីជោគជាំដោយសារទឹកភ្លៀងឬទឹកជំនន់។

## IV. គម្រោងដាំស្ពៃក្រញ៉ាញ់

មុនពេលចាប់ផ្តើមដាំស្ពៃក្រញ៉ាញ់យើងត្រូវរៀបចំគម្រោងសម្រាប់ដាំដូចខាងក្រោមនេះ៖

១- ជាដំបូងជ្រើសរើសទីតាំងដីសម្រាប់ដាំដុះ បន្ទាប់មកកាប់គាស់ភ្ជួររាស់និងហាលដីប្រហែល១សប្តាហ៍

២- មានប្រភពទឹកសម្រាប់ប្រើប្រាស់

៣- មានពូជល្អ

៤- មានជីធម្មជាតិសម្រាប់ប្រើប្រាស់និងថ្នាំការពារ

៥- មានឧបករណ៍ពាក់ព័ន្ធដូចជា ចប ឡាំង បង្គី និងកម្លាំងអូសទាញ។ល។

៦- ចំណុចសំខាន់មួយទៀតគឺកម្លាំងពលកម្មសម្រាប់ថែទាំនិងមានបច្ចេកទេសនិងមានថវិកាផងដែរ។

## V. វិធីសាស្ត្រ ឬបច្ចេកទេសនៃការដាំស្ពៃក្រញ៉ាញ់

យើងមានបច្ចេកទេសសម្រាប់ដាំស្ពៃក្រញ៉ាញ់ដូចខាងក្រោម៖

កាលបរិច្ឆេទៈ ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៨

១- កាប់គាស់ភ្ជួររាស់និងហាលដីរយៈពេលប្រហែល១សប្តាហ៍ជាមុនសិន
២- លើករងដាំៈ ទទឹងរងយកប្រវែង១ម៉ែត្រ បណ្តោយប្រវែង៥ទៅ១០ម៉ែត្រ និងកំពស់រងយកប្រវែង១០សង់ទីម៉ែត្រ(១តឹក)។
៣- ដាក់ជីធម្មជាតិប្រមាណជា៧ឬ៨គីឡូក្រាមសម្រាប់ទំហំដី១ម៉ែត្រការេ ហើយត្រូវច្របល់ជីនិងដីនោះឱ្យសព្វនៅក្នុងរង។
៤- យកគ្រាប់ពូជមកខ្ចប់ជាមួយនឹងក្រណាត់រួចត្រាំទឹក១យប់ ហើយដាក់ផ្អាប់វារយៈពេល៧ម៉ោងបន្ទាប់មកយកវាទៅសាបជាការស្រេច។
៥- ស្រោចទឹកដំណាំនេះ១ថ្ងៃ២ដងនៅពេលព្រឹកនិងពេលល្ងាច ព្រមទាំងថែទាំវាជាប្រចាំ៕

**សូមអរគុណ**

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

កាលបរិច្ឆេទៈ ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៨

# មេរៀនដំណាំត្រសក់ស្រូវទ្រើង

## I. ប្រវត្តិសង្ខេបនៃការដាំត្រសក់ស្រូវទ្រើង

ដំណាំត្រសក់ស្រូវទ្រើងគឺជាដំណាំងាយស្រួលដាំ ហើយជាទូទៅកសិករភាគច្រើនចូលចិត្តយកវាមកធ្វើជាបន្លែឬជាអន្លក់ ហើយនិងយកវាមកដាំស្លសម្រាប់អាហារទទួលទានជាប្រចាំនៅក្នុងគ្រួសារ។

## II. ការអះអាងទៅលើការសិក្សាស្រាវជ្រាវអំពីដំណាំត្រសក់ស្រូវ

បើយោងទៅតាមអ្នកកត់ត្រាផ្នែកដាំដុះនិងអ្នកផលិតគ្រាប់ពូជបានអះអាងជាទូទៅថា«អាយុកាលរបស់ដំណាំត្រសក់ស្រូវគឺមានអាយុ៤៥ថ្ងៃអាចប្រមូលផលបានដោយចាប់រាប់តាំងពីចាប់ផ្តើមដាំរហូតដល់ទទួលបានផ្លែផ្កា។ យើងអាចប្រមូលឬបេះផ្លែត្រសក់ស្រូវបានជាបន្តបន្ទាប់រហូតដល់៨០ថ្ងៃទើបវាអស់ផ្លែ»។

## III. តម្រូវអាកាសធាតុ

ដំណាំត្រសក់ស្រូវត្រូវការកំដៅចាប់ពី៩០ទៅ១០០ភាគរយ ដើម្បីទ្រទ្រង់សរីរាង្គរបស់វា។ លើសពីនោះទៅទៀត ដំណាំនេះក៏ត្រូវការទឹកនិងសំណើមត្រជាក់ដែរ ប៉ុន្តែត្រូវជៀសវាងការប្រើប្រាស់ទឹកជោគជាំហួសពី

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

តម្រូវការរបស់វា។ នៅក្នុងខណៈពេលដែលមានទឹកជោគជាំវានឹងបណ្តាលឱ្យដើម គល់ និងឫសរបស់វាងាយរលួយ ហើយផ្លែផ្ការបស់វាក៏អាចថយចុះដែរ។

## IV. ភូមិសាស្ត្រសម្រាប់ដាំត្រសក់ស្រូវ

យើងអាចដាំត្រសក់ស្រូវនៅលើទីតាំងដីល្បាយខ្សាច់ ដីកណ្តោង (ដីមានជីជាតិ ដីខ្មៅ គ្មានជាតិកំបោរនិងជាតិប្រៃ) ដីក្រហម ដីទួលដីដំបូក ឬដីស្រែចំការ។

### *ចំណុចសំខាន់និងចំណុចពិសេសរបស់ដំណាំត្រសក់ស្រូវ*

- ត្រូវជៀសវាងការដាំវានៅលើដីទំនាបលិចទឹកជោគជាំនៅរដូវវស្សា។
- គេអាចដាំវាបាននៅគ្រប់រដូវកាល ហើយដំណាំនេះងាយស្រួលដាំ ប៉ុន្តែវាក៏អាស្រ័យលើបច្ចេកទេសដាំ រួមទាំងមានប្រភពដីនិងប្រភពទឹកសម្រាប់ស្រោចស្រប់ផងដែរ។

## V. គម្រោងដាំត្រសក់ស្រូវ

មុនពេលចាប់ផ្តើមដាំត្រសក់ស្រូវ យើងត្រូវរៀបចំគម្រោងសម្រាប់ដាំដូចខាងក្រោមនេះ៖

១- ជាដំបូងជ្រើសរើសទីតាំងដីសម្រាប់ដាំដុះ បន្ទាប់មកកាប់គាស់ភ្ជួររាស់និងហាលដីប្រហែល១សប្តាហ៍ឬលើសពីនេះ

២- មានប្រភពទឹកសម្រាប់ប្រើប្រាស់
៣- មានពូជនិងទ្រើងសម្រាប់ឱ្យវាវារឡើង
៤- មានជីធម្មជាតិសម្រាប់ប្រើប្រាស់និងថ្នាំសម្រាប់ការពារ
៥- មានឧបករណ៍ពាក់ព័ន្ធដូចជា ចប ឡាំង បង្គី និងកម្លាំងអូសទាញ។ល។
៦- ចំណុចសំខាន់គឺមានកម្លាំងសម្រាប់ថែទាំ មានបច្ចេកទេស និងមានថវិកាផង។

## VI. វិធីសាស្ត្រ ឬបច្ចេកទេសនៃការដាំត្រសក់ស្រូវ

យើងមានបច្ចេកទេសសម្រាប់ដាំត្រសក់ស្រូវដូចខាងក្រោម៖

*១-ការរៀបចំដី៖* កាប់គាស់ភ្ជួររាស់និងហាលដីប្រហែល១សប្តាហ៍ជាមុនសិនដើម្បីធ្វើឱ្យដីអស់មេរោគនិងសំបូរអុកស៊ីសែន។

*២-ការលើករងដាំ៖* កំពស់រងយកប្រវែង១0សង់ទីម៉ែត្រ(១តឹក)ទទឹងរងយកប្រវែងកន្លះម៉ែត្រនិងបណ្តោយរងយកប្រវែង៥ទៅ២0ម៉ែត្រឬអាស្រ័យទៅនឹងទំហំដីដែលយើងមាន។

**ចំណាំ៖** ទ្រូងរងនីមួយៗត្រូវទុកគម្លាតពីគ្នាប្រវែង៥0សង់ទីម៉ែត្រ (៥តឹក) ងាយស្រួលដើរថែទាំ។

*៣-កាប់ចង្អូរ៖* ត្រូវកាប់ចង្អូរពុះចំពាក់កណ្តាលរង ហើយនៅក្នុងផ្ទៃរងនោះក្លាយទៅជាកូនប្រឡាយតូចមួយដោយយកជម្រៅ២តឹកនិងទទឹង២តឹក។

*៤-ការប្រើជីធម្មជាតិ៖* ដំបូងចូរដាក់ជីធម្មជាតិជារបាយតាមរណ្ដៅចង្អូរដើម្បីជួយជម្រុញដីឲ្យមានជីជាតិបន្ថែម។

ការបញ្ជាក់ពីកំរិតប្រើជីធម្មជាតិគោក៖ ជាទូទៅយើងអាចប្រើពី៧ទៅ៨គីឡូក្រាមសម្រាប់ទំហំផ្ទៃដី១ម៉ែត្រការ៉េ។ នេះជាការប្រសើរដើម្បីឲ្យមានតុល្យភាពជាមួយនឹងដីធម្មជាតិ។

*៥-ការត្រាំគ្រាប់ពូជ៖* មុនពេលដាំត្រសក់ស្រូវត្រូវយកគ្រាប់ពូជមកខ្ចប់ជាមួយនឹងកំណាត់ហើយត្រាំទឹក១យប់ក្នុងធុងទឹកកកដើម្បីឲ្យពូជឆាប់ដុះ។

*៦-ការផ្អាប់គ្រាប់ពូជ៖* ត្រូវយកគ្រាប់ពូជនោះមកផ្អាប់១យប់បន្តទៀតក្នុងធុងទឹកកកណាដែលមានជាតិស្មោហើយបិទគំរបឲ្យជិត។ ធុងនោះត្រូវយកមកដាក់ឲ្យចំកំដៅថ្ងៃដើម្បីឲ្យពូជនោះងាយដុះពន្លកបានល្អ។

*៧-ការដាំដុះ៖* យកគ្រាប់ពូជនោះមកដាំ ក្នុង១រណ្ដៅអាចដាក់ពី២ឬ៣គ្រាប់ហើយកប់វាកំណត់ជម្រៅ៣សង់ទីម៉ែត្រ និងគម្លាតពីគុម្ពមួយទៅគុម្ពមួយយកប្រវែង១ម៉ែត្រ៣តឹកជាការគ្រប់គ្រាន់ ចុងក្រោយស្រោចទឹកព្រឹកល្ងាច។

*៨-ការដាក់ទ្រើង៖* នៅពេលត្រសក់ស្រូវដុះបានពី៤ថ្ងៃឬ៥ថ្ងៃផុតពីរណ្ដៅ ចូរដាក់ទ្រើងឱ្យត្រសក់ស្រូវវារឡើង។

កាលបរិច្ឆេទៈ ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៨

*៩-ការថែទាំៈ* តាមដាននិងស្រោចទឹកមួយថ្ងៃ២ដងនៅពេលព្រឹក និងពេលល្ងាច និងថែទាំជាប្រចាំដូចជាបោចស្មៅដាក់ជីនិងបាញ់ថ្នាំថែបំប៉នបន្ថែមដើម្បីឲ្យឆាប់បានទទួលផល៕

**សូមអរគុណ**

រៀបចំដោយលោក ភួង សាលី នាយកប្រតិបត្តិរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)